# English for Study in Australia

## កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

LESSON 24– Graduation

មេរៀនទី២៤ ៖ ការទទួលសញ្ញាបត្រ

**STUDY NOTES**

**ឯកសារជំនួយមេរៀន**

**តួអង្គ**

Rocky:
រ៉ុកឃី ៖ និស្សិតអន្តរជាតិ
John:
ចន ៖ និស្សិតបរទេស
Carmel :
ខាម៉ល ៖ ស្ត្រីម្ចាស់ផ្ទះដែលចន និងរ៉ុកឃីស្នាក់នៅជាមួយ
Alan Smythe:
អេឡិន ស្មាយត៍ ៖ គ្រូបង្រៀនរបស់ចន
Chancellor:
សកលវិទ្យាធិការ៖ នៅសកលវិទ្យាល័យ

**សាច់រឿង**

ខាម៉ល ចន និងរ៉ុកឃី បានជាប់ស្ទះចរាចរណ៍យ៉ាងណែនណាំតាន់តាប់ នៅពេលពួកគេធ្វើដំណើរទៅចូលរួមការប្រគល់សញ្ញាបត្រនៅសាកលវិទ្យាល័យរបស់ចន។ ចន ជិះកង់ទៅមុន ហើយក៏ទៅដល់ទាន់ពេលល្មមដែលពិធីប្រគល់សញ្ញាបត្រចាប់ផ្តើម។

**ព័ត៌មាន-វាក្យសព្ទសម្រាប់ការប្រគល់សញ្ញាបត្រ**

| | |
|---|---|
| Graduand | ពាក្យនេះគឺគេប្រើសម្រាប់ហៅនិស្សិតដែលរៀនចប់ទៅទល់នឹងពេលដែលនិស្សិតទទួលសញ្ញាបត្រ |
| Academic gown | និស្សិតដែលបញ្ចប់ការសិក្សា ត្រូវជួលសម្លៀកបំពាក់ឯកសណ្ឋានជាផ្លូវការ ដើម្បីពាក់នៅពេលឡើងទទួលសញ្ញាបត្រ។ ជាធម្មតា ឯកសណ្ឋាននេះមានពណ៌ខ្មៅ ប៉ុន្តែនិស្សិតដែលនឹងទទួលសញ្ញាបត្រថ្នាក់បណ្ឌិត នឹងពាក់ឯកសណ្ឋានពណ៌ផ្សេងពីនេះ។ |


© RadioAustralia/AMES 2008

| | |
|---|---|
| Mortarboard, trencher | មួកដែលមានផ្នែកខាងលើរាងសំប៉ែត ដែលអ្នកទទួលសញ្ញាបត្រមួយចំនួនពាក់ជាមួយឯកសណ្ឋានទទួលសញ្ញាបត្រ។ |
| Testamur | សញ្ញាបត្របញ្ជាក់ជាផ្លូវការសម្រាប់ការបញ្ចប់ a degree or diploma or certificate របស់និស្សិត (មានន័យថាជាឯកសារសញ្ញាបត្រ) |

## ភាសា-សំនួនវោហារ និងឃ្លាប្រយោគដែលមានន័យមិនធម្មតា

| | |
|---|---|
| Chockers (chockablock) | ស្ទះ ឬជាប់គាំងពេញតែម្តង។ ការស្ទះចរាចរណ៍ ត្រូវបានពិពណ៌នាថាជា chockers (ការស្ទះកកកុញ)។ |
| To cut it fine | មិនសល់ពេលសម្រាប់ដោះស្រាយហេតុការណ៍ចៃដន្យដែលអាចកើតឡើង |
| (a) hold up | អ្វីមួយដែលស្ទះរាំងដល់ដំណើរវិវឌ្ឍរបស់លោកអ្នក។ |
| Up ahead | នៅក្នុងចម្ងាយគួរសមខាងមុខអ្នក។ |
| Just in case | គ្រាន់តែជាវិធានការបង្ការ ក្រែងលោមានអ្វីកើតឡើង។ |
| "All the best" | សូមជូនពរឲ្យមានសំណាងល្អ! |
| Grab a bite | ទៅរកអីញ៉ាំ/ទទួលទាន។ |

## លំហាត់

### ១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| academic | achievement | certificate |
| deposit | diploma | future |
| gown | hall | instruction |


© RadioAustralia/AMES 2008

| | | |
|---|---|---|
| medal | professional | proud |
| (to) queue | route | starving |
| suit | traffic | unbelievable |

## ២. ការហាត់រៀនភាសា លំហាត់គំរូ តេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស ជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word (or phrase) that best completes each sentence.
ចូរជ្រើសពាក្យដែលសមរម្យបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះនៃអត្ថបទក្នុងប្រអប់ខាងក្រោម។

សូមគូសខ្វែងនៅក្នុងប្រអប់មួយសម្រាប់លេខនីមួយៗ ឧទាហរណ៍ ☒

1. How _________ __________ the deposit?

☐ much is ☐ much ☐ cost ☐ price

2. Can I ____________ you by credit card?

☐ cost ☐ price ☐ pay ☐ give

3. Congratulations _________ your achievement.

☐ in ☐ on ☐ for ☐ by

4. All the best ___________ the future.

☐ for ☐ about ☐ by ☐ over

5. Thanks for your _______________.

☐ helping ☐ help me ☐ help ☐ helper

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

ភាពខុសគ្នារវាងពាក្យអ្នករៀនចប់គឺ graduate (ជានាម) និងការប្រគល់សញ្ញាបត្រ graduate (ជាកិរិយាសព្ទ) ៖ សូមហាត់និយាយពាក្យនេះ ដោយត្រូវប្រឹងពត់អណ្តាតរួចបញ្ចេញសំឡេងឲ្យបានឮៗ ៖

**“Did the graduate graduate gracefully?”**


© RadioAustralia/AMES 2008

## ៩. អាសយដ្ឋានអ៊ីនធើរណិតដែលមានប្រយោជន៍

| | |
|---|---|
| **ព័ត៌មាន ៖** ការទទួលសញ្ញាបត្រនៅពេលបញ្ចប់ការសិក្សានៅសកលវិទ្យាល័យប្រទេសអូស្ត្រាលី | University of Sydney<br>http://www.usyd.edu.au/studentcentre/forms/grads/Information_for_Graduands.pdf<br><br>Macquarie University (NSW)<br>http://www.graduation.mq.edu.au/<br><br>University of Melbourne<br>http://www.studentadmin.unimelb.edu.au/graduations/<br><br>Latrobe University (Victoria)<br>http://www.latrobe.edu.au/acadserv/current/grad_handbook.html#dress<br><br>University of South Australia<br>http://www.unisa.edu.au/studysas/graduations/GraduationCeremonyInformation.doc<br><br>University of Western Australia<br>http://www.studentadmin.uwa.edu.au/welcome/graduation/p3<br><br>University of Tasmania<br>http://graduation.admin.utas.edu.au/<br><br>University of Queensland<br>http://www.uq.edu.au/graduations/graduation-day-schedule |
| សារតារនៃសម្លៀកបំពាក់ទទួលសញ្ញាបត្រ | http://www.graduation.mq.edu.au/dress_hire.htm |

ចម្លើយលំហាត់ទី 2:  1) much is    2) pay    3) on    4) for    5) help

ABC Radio Australia
radioaustralia.net.au
AMES
www.ames.net.au
© RadioAustralia/AMES 2008